# សុន្ទរកថារបស់ ឯកឧត្តម ហូរីណូអ៊ិជិ ហ៊ីដេហ៊ីសា
# ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងពិធីបើកសម្ពោធមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញ
# ក្នុងតុលាការកម្ពុជា

*ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧*

- សូមគោរព **ឯកឧត្តម ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
- សូមគោរព **លោកស្រី ជា សាវុន** ប្រធានមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
- សូមគោរព ឯកឧត្តម ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត លោក លោកស្រី

ខ្ញុំមានសេចក្តីរីករាយណាស់ ដោយបានចូលរួមក្នុងពិធីបើកសម្ពោធមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ (LDC) នេះ។ ជាមួយគ្នានេះ ខ្ញុំសូមចូលរួមសម្តែងមរណៈទុក្ខចំពោះក្រុមគ្រួសារ មិត្តភក្តិ និងសហការីរបស់សម្តេចវិបុលបញ្ញា **សុខ អាន** ដែលសម្តេចបានរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើត LDC នេះឡើង រហូតដល់ពេលដែលសម្តេចទទួលមរណៈភាពនាថ្ងៃទី15 ខែមីនា។

ប្រទេសជប៉ុន ដែលជាមិត្តយូរអង្វែងរបស់កម្ពុជា បានដើរតួនាទីយ៉ាងសកម្មក្នុងការលើកស្ទួយការផ្សះផ្សា និងការកសាងជាតិឡើងវិញរបស់កម្ពុជា ហើយថែមទាំងបានផ្តោតសារៈសំខាន់ទៅលើសាលាក្តីខ្មែរក្រហម។ កិច្ចខិតខំប្រឹងប្រែងនេះ គឺជាការបិទទំព័រនៃដំណើរការស្វែងរកសន្តិភាពរបស់កម្ពុជាទាំងមូល និងការផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ក៏ដូចជាក្រុមគ្រួសាររបស់គេ ព្រមទាំងពង្រឹងនីតិរដ្ឋនៅកម្ពុជា។ ដោយផ្អែកលើទស្សនៈទាំងនេះ ជប៉ុនបានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបុគ្គលិកដល់សាលាក្តីតាំងពីពេលចាប់ផ្តើមដំបូង ហើយក៏ជាម្ចាស់ជំនួយធំជាងគេរហូតមកដល់ពេលបច្ចុប្បន្ននេះ។

យើងជឿជាក់យ៉ាងមុតមាំថា LDC ដែលបើកដំណើរការថ្ងៃនេះ នឹងមានតំលៃដ៏ធំធេងសំរាប់ការអភិរក្សកេរ្តិ៍ដំណែលនៃសាលាក្តីខ្មែរក្រហម។ មជ្ឈមណ្ឌលនេះ នឹងមានតួនាទីដ៏មានអត្ថន័យក្នុងការផ្ទេរការពិតដែលសាលាក្តីបានរកឃើញពីមួយជំនាន់ទៅមួយជំនាន់ទៀត។ LDC នឹងធ្វើអោយកាន់តែប្រសើរឡើងសម្រាប់ប្រជាពលរដ្ឋក្នុងការទទួលបានឯកសារសាធារណៈទាក់ទងនឹងសាលាក្តីខ្មែរក្រហម និងសម្របសម្រួលដល់ការផ្សព្វផ្សាយសំលេងជនរងគ្រោះទៅដល់សាធារណៈជនទូទៅ។

ដោយសារហេតុផលទាំងនេះ ជប៉ុនបានសម្រេចគាំទ្រ LDC ហើយក៏បានផ្តល់ថវិកាប្រហែល 2,400,000 (ពីរលានបួនសែន) ដុល្លាសហរដ្ឋអាមេរិក សំរាប់គម្រោងនេះ។

ដើម្បីកុំឲ្យសោកនាដកម្មនាពេលអតីតកាលកើតមានឡើងទៀត ខ្ញុំចង់ឲ្យ LDC ត្រូវបានប្រើប្រាស់ដោយប្រជាពលរដ្ឋគ្រប់លំដាប់ ដែលរួមមានជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកសិក្សាពីគ្រប់វិស័យ។ ខ្ញុំក៏សង្ឃឹមថាជំនួយរបស់ជប៉ុននេះ នឹងជួយពង្រឹងបន្ថែមទៀតនូវទំនាក់ទំនងមិត្តភាពដ៏ជិតស្និទ្ធរវាងជប៉ុននិងកម្ពុជា។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!**